# អង្គការសហប្រជាជាតិ

## សេចក្តីប្រកាសព័ត៌មាន

## ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សំដែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្សលោកគឹម សុខា និង លោកយ៉េង វីរៈ

ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០៦

ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង នៅពេលដែលបានទទួលដំណឹងអំពីការចាប់ខ្លួន និងការឃុំខ្លួន លោកគឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង លោកយ៉េង វីរៈ នាយកមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ ពីបទបរិហារកេរ្តិ៍ ។ នេះគឺជាការចាប់ខ្លួនថ្មីៗបំផុតដែលទាក់ទងនឹងបណ្តឹងបរិហារកេរ្តិ៍ ការញុះញង់ និងការផ្សព្វផ្សាយព័ត៌មានមិនពិត និងការចាប់ខ្លួនសមាជិកទាំងឡាយនៃសង្គមស៊ីវិល សហជីពកម្មករ សារព័ត៌មាន និងគណៈបក្សប្រឆាំងសមរង្ស៊ី នៅក្នុងដំណាច់ឆ្នាំកន្លងទៅនេះ ។ និន្នាការដែលគួរអោយរំខាននេះ គំរាមកំហែងដល់ការស្តារឡើងវិញនូវភាពជឿនលឿនទៅមុខដែលត្រូវបានធ្វើឡើង តាមរយៈកិច្ចខិតខំប្រឹងប្រែងពុះពាររាល់ការលំបាកក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ដើម្បីកសាងឱ្យមានសង្គមមួយយុត្តិធម៌ និងបើកចំហ ដោយផ្អែកលើគោលការណ៍នីតិរដ្ឋ ។ សហគមន៍អន្តរជាតិដែលបានគាំទ្រប្រទេសកម្ពុជាយ៉ាងខ្លាំងក្លា នៅលើវិថីនេះចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១មក មានហេតុផលក្នុងការព្រួយបារម្ភយ៉ាងខ្លាំងអំពីព្រឹត្តិការណ៍ទាំងនេះ ។

ខ្ញុំសូមរំលឹកថា ប្រទេសកម្ពុជាគឺជាភាគីមួយនៃសន្ធិសញ្ញាអន្តរជាតិសំខាន់ៗទាំងអស់ស្តីពីសិទ្ធិមនុស្ស ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវមានកាតព្វកិច្ចគោរព និងធានាឱ្យបាននូវការអនុវត្តន៍សិទ្ធិនានា ដែលមានចែងនៅក្នុងសិទ្ធិសញ្ញាទាំងនោះ រាប់បញ្ចូលទាំងសិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបប្រជុំដែលជាមូលដ្ឋានគ្រឹះសំរាប់សង្គមប្រជាធិបតេយ្យ ហើយនេះគឺជាលក្ខខណ្ឌពិសេស សំរាប់វឌ្ឍនៈភាពរបស់ខ្លួន ។ សង្គមស៊ីវិលដ៏រឹងមាំរបស់កម្ពុជាមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយជំរុញកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីងើបចេញឱ្យផុតពីអតីតកាលដ៏រីករវរបស់ខ្លួន ។ សមត្ថភាពរបស់សង្គមស៊ីវិលក្នុងការបំពេញការងារដ៏សំខាន់របស់ខ្លួន និងក្នុងការបន្តរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ត្រូវតែបានធានា និងទទួលការគាំទ្រ ។